ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៤៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតអនុគណៈកម្មាធិការជំនួយសង្គម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៥៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើត “អនុគណៈកម្មាធិការជំនួយសង្គម” ដែលជាសេនាធិការរបស់គណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការជំនួយសង្គម។

## ជំពូកទី២

## ការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការជំនួយសង្គម

**មាត្រា៣ .-**

អនុគណៈកម្មាធិការជំនួយសង្គម មានសមាសភាពដូចតទៅ ÷

| | |
|---|---|
| ១- រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ប្រធាន |
| ២- តំណាងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | អនុប្រធាន |
| ៣-អគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម | អនុប្រធាន |
| ៤- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥- តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៦- តំណាងក្រសួងការពារជាតិ | សមាជិក |
| ៧- តំណាងក្រសួងផែនការ | សមាជិក |
| ៨- តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៩- តំណាងក្រសួងសុខាភិបាល | សមាជិក |
| ១០- តំណាងក្រសួងយុត្តិធម៌ | សមាជិក |
| ១១- តំណាងក្រសួងកិច្ចការនារី | សមាជិក |
| ១២- តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៣-តំណាងក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៤- តំណាងអគ្គនាយកដ្ឋានគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៥- តំណាងអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៦- តំណាងអគ្គនាយកដ្ឋានបច្ចេកទេស នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |

អនុគណៈកម្មាធិការជំនួយសង្គម អាចមានសមាសភាពបន្ថែម តាមការចាំបាច់។ សមាសភាពជាក់ស្តែងរបស់អនុគណៈកម្មាធិការជំនួយសង្គម ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។

**មាត្រា៤ .-**

អនុគណៈកម្មាធិការជំនួយសង្គម មានលេខាធិការដ្ឋាននៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាសេនាធិការក្នុងការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន។

លេខាធិការដ្ឋានរបស់អនុគណៈកម្មាធិការជំនួយសង្គម ត្រូវសហការ សម្របសម្រួលផ្តល់ព័ត៌មាន និងរបាយការណ៍នានា ដល់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។

**មាត្រា៥ .-**

អនុគណៈកម្មាធិការជំនួយសង្គម មានតួនាទី និងភារកិច្ច ដឹកនាំសម្របសម្រួលការងារបច្ចេកទេស ដើម្បីគាំទ្រដល់ការបំពេញមុខងាររបស់គណៈកម្មាធិការប្រតិបត្តិ ដូចខាងក្រោម ÷

- គាំទ្រដល់ការដឹកនាំសម្របសម្រួលការអនុវត្តកម្មវិធីជំនួយសង្គម ស្របតាមក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម
- សិក្សាស្រាវជ្រាវ និងដកស្រង់បទពិសោធន៍ ពីបណ្តាប្រទេសនានា អំពីប្រព័ន្ធជំនួយសង្គម
- រៀបចំផែនការអប់រំ ផ្សព្វផ្សាយ និងលើកកម្ពស់ចំណេះដឹងដល់ប្រជាពលរដ្ឋអំពីប្រព័ន្ធជំនួយសង្គម
- គាំទ្រដល់ការតាមដាន ត្រួតពិនិត្យការអនុវត្ត និងវាយតម្លៃវឌ្ឍនភាពនៃការអភិវឌ្ឍប្រព័ន្ធជំនួយសង្គម
- សម្របសម្រួល និងរៀបចំរបាយការណ៍វឌ្ឍនភាពការងារប្រព័ន្ធជំនួយសង្គម ជូនគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- សិក្សាអំពីលទ្ធភាពក្នុងការរៀបចំបង្កើតប្រតិបត្តិករជំនួយសង្គម
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនពីប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម និងប្រធានគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម។

**មាត្រា៦ .-**

អនុគណៈកម្មាធិការជំនួយសង្គម ត្រូវរៀបចំកិច្ចប្រជុំរៀងរាល់ ០៣ខែម្តង ឬក្នុងករណីចាំបាច់ តាមការអញ្ជើញរបស់ប្រធាន។

ក្នុងករណីអវត្តមាន ប្រធានអនុគណៈកម្មាធិការជំនួយសង្គម អាចផ្ទេរសិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំកិច្ចប្រជុំជំនួស តាមការចាំបាច់។

អនុប្រធាន និងសមាជិករបស់អនុគណៈកម្មាធិការជំនួយសង្គម ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬត្រូវចាត់តំណាងដែលមានសិទ្ធិសម្រេចឱ្យចូលរួមប្រជុំជំនួស ក្នុងករណីអវត្តមាន។

អនុគណៈកម្មាធិការជំនួយសង្គម អាចអញ្ជើញ តំណាងក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន និងសង្គមស៊ីវិលពាក់ព័ន្ធនានា ដើម្បីពិភាក្សាការងារក្នុងគោលដៅជំរុញវឌ្ឍនភាពនៃការអភិវឌ្ឍប្រព័ន្ធជំនួយសង្គម តាមការចាំបាច់។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៦ កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ